ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
លេខ.......................“ជ១” ដ.ជ
ចុះថ្ងៃទី..០៤..ខែកុម្ភៈ ឆ្នាំ២០២១

# ដីកាសម្រេច

## បញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង [redacted] ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោកស្រី [redacted] ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ មាត្រា២៤៧ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧, មាត្រា២៦៨, មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ; មាត្រា២៥០ និងមាត្រាដែលពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។
- បានឃើញ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/ ១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។
- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៦២៧៤ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ ។
- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៦៣ អ.យ.ណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ។
- បានឃើញ សំណុំរឿងស៊ើបសួរលេខ ៧៥៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ។
- បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៣១៨ អ.យ.ឥ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចចោទប្រកាន់លើ ៖

១-ឈ្មោះ [redacted] រចនា ភេទប្រុស អាយុ៣៩ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមន្ត្រីនគរបាលជាតិ ទីកន្លែងកំណើត ភូមិ [redacted] ស្រុកកំចាយមារ ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] “ស្លាប់” ម្តាយឈ្មោះ [redacted] “ស្លាប់” ប្រពន្ធឈ្មោះ [redacted] មានកូន០៤នាក់ ទោសពីមុនគ្មាន ជានីតិជន។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៥ “ជ១” ដ.ព.ស ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ។

២-ឈ្មោះ [redacted] សាវន់ ភេទប្រុស អាយុ៥១ឆ្នាំ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង មុខរបរប្រធានការិយាល័យ ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] “ស្លាប់” ម្តាយឈ្មោះ [redacted] “ស្លាប់” ប្រពន្ធឈ្មោះ [redacted] មានកូន០៣នាក់ ទោសពីមុនគ្មាន ជានីតិជន។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៤ “ជ១” ដ.ព.ស ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ។

៣-ឈ្មោះ [redacted] សុខុម ភេទប្រុស អាយុ៥៤ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមន្ត្រីរាជការ ទីកន្លែងកំណើត [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] “ស្លាប់” ម្តាយឈ្មោះ [redacted] “ស្លាប់” ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។



Scanned with CamScanner

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៣ "ជ១" ដ.ព.ស ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ។

៤-ឈ្មោះ [redacted] សុវណ្ណ ភេទប្រុស អាយុ២៩ឆ្នាំ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតភូមិ [redacted] ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅភូមិ [redacted] ខេត្តព្រៃវែង ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] ទោសពីមុនគ្មាន ជានីតិជន ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ ៦៧៦៣ "ជ១" ដ.ព.ស ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ។

ពីបទ៖ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

## សំអាងហេតុ

១-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] សុខុម បានឆ្លើយប្រហាក់ប្រហែលគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធីថា៖ ឈ្មោះ [redacted] រចនា បានបបួលខ្លួនឲ្យចូលរួមរៀបចំទិញដីដែលស្ថិតនៅឃុំក្របៅ និងឃុំក្រញូង ឲ្យទៅក្រុមហ៊ុនមួយក្នុងតម្លៃ ៤៥០០ ក្នុងមួយហិចតា ដោយឲ្យខ្លួនគ្រាន់តែឈរឈ្មោះ ប៉ុណ្ណោះ រាល់ការទិញ និងរៀបចំឯកសារ គឺឈ្មោះ [redacted] រចនា ជាអ្នករៀបចំ ។ ខ្លួនត្រូវបានគេហៅឲ្យចូលរួមនៅពេលដែលទទួលបានសែកពីម្ចាស់លុយ ដោយឲ្យខ្លួនផ្តិតមេដៃដឹងលឺដែរ ។ ចំពោះការទិញដីបានប៉ុន្មានហិចតា និងការទទួលលុយជាសែកពីក្រុមហ៊ុនប៉ុន្មាន គឺខ្លួនពុំដឹងឡើយ ។ កន្លងមកឈ្មោះ [redacted] រចនា ធ្លាប់សន្យាជាមួយខ្លួនថាជាអ្នកទទួលខុសត្រូវទាំងស្រុងតែម្នាក់ឯង ដោយពុំឲ្យខ្លួនពាក់ព័ន្ធឡើយ ដូចមានក្នុងលិខិតបញ្ជាក់របស់ឈ្មោះ [redacted] រចនា ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ស្រាប់ ។

២-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] រចនា បានឆ្លើយប្រហាក់ប្រហែលគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធីថា៖ ចំពោះលុយជាង២លានដុល្លារអាមេរិកនេះ គឺក្រុមខ្លួនបានទទួលជាសែកដែលចេញមកឲ្យខ្លួនទៅបើកលុយឲ្យទៅម្ចាស់ដី និងខ្លះទៀតក្រុមហ៊ុនបានចេញឲ្យទៅម្ចាស់ដីផ្ទាល់ ។ ដីដែលត្រូវបានទិញក្នុងកិច្ចសន្យាគឺ ២៣ជាង ទិញបានជាង៤០០ហិចតា ក្នុងតម្លៃ ៤៥០០$ ក្នុង១ហិចតា ប៉ុន្តែពេលទៅទិញផ្ទាល់ជាក់ស្តែងដីខ្លះ ឡើងដល់១០,០០០ដុល្លារអាមេរិក ខ្លះ ១៥០០០ ខ្លះ ១៨០០០ ដុល្លារអាមេរិក ទៀត ទើបធ្វើឲ្យការទិញពុំគ្រប់ចំនួនតាមការកំណត់ក្នុងកិច្ចសន្យា ហើយពួកខ្លួនទិញបានតែ ៣៨ហិចតា នៅក្នុងឃុំក្របៅ, ៦៨ហិចតា នៅក្នុងឃុំក្រញូង និងនៅតាមផ្លូវជាតិ៨អា ក្នុងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ជិត២ហិចតាទៀត សរុបប្រហែល ១០៨ហិចតា ។ ក្នុងលុយជាង ២លានដុល្លារអាមេរិក ខ្លួនទិញដីអស់ នៅសល់ប្រហែល៧០០,០០០ (ចិតសិបម៉ឺនដុល្លារអាមេរិក)គឺចំណាយទៅលើការរត់ការកាត់ឈ្មោះ និងថ្លៃចាយវាយផ្សេងអស់ហើយ ។ ចំពោះដី៦៨ហិចតា នៅឃុំក្រញូង ពួកខ្លួន និងក្រុមហ៊ុនពិតជាបានចុះវាស់វែង និងផ្ទេរសិទ្ធិជូនក្រុមហ៊ុនរួចដោយរត់ទៅសូរិយោដីហើយ តែចេញប្លង់បានឬអត់ខ្លួនពុំដឹងទេ , ៣៨ហិចតាទៀត ផ្ទេរបានត្រឹមស្រុក និង២ហិចតាចុងក្រោយផ្ទេរត្រឹមឃុំ ។

៣-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] សារន់ បានឆ្លើយប្រហាក់ប្រហែលគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធីថា៖ ខ្លួនបានចូលរួមជាក្រុមការងារទិញដីពីប្រជាពលរដ្ឋជាមួយឈ្មោះ [redacted] រចនា ដោយគ្រាន់តែឈរឈ្មោះ ហើយខ្លួនពុំបានចុះទៅវាស់វែង ឬទៅទិញពីម្ចាស់ដីផ្ទាល់ទេ ខ្លួនគ្រាន់តែបានទៅទទួលសែកពីក្រុមហ៊ុនប៉ុណ្ណោះ ។ ចំនួនលុយសរុបដែលក្រុមហ៊ុនទម្លាក់ឲ្យជាសែកសរុបប្រហែល ២លានដុល្លារអាមេរិក ដោយតម្រូវឲ្យទិញដីជាង ៣០០ហិចតា ពេលនោះគឺ១ហិចតា ៤៥០០ដុល្លារអាមេរិក តែការទិញជាក់ស្តែងបានប្រហែ១០ហិចតា ប៉ុណ្ណោះក៏អស់លុយ ។ ខ្លួនពុំបានដឹងថាឈ្មោះម៉ាន់ រចនា យកលុយទៅធ្វើអ្វីខ្លះនោះទេ ព្រោះគាត់ជាអ្នកគ្រប់គ្រងលុយដែលក្រុមហ៊ុនបើកឲ្យ ។ មូលហេតុដែលទិញដីមិនគ្រប់តាមកិច្ចព្រមព្រៀង ដោយសារដីឡើងថ្លៃជាបន្តបន្ទាប់ ហើយម្ចាស់លុយក៏បានឯកភាពតាមលុយនោះដែរ ។ ន៍



Scanned with CamScanner

៤-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] សុវណ្ណ បានឆ្លើយប្រហាក់ប្រហែលគ្នានៅគ្រប់ដំណាក់កាលនៃនីតិវិធីថា៖ ក្រុមការងាររបស់ខ្លួនមានរូបខ្លួន ឈ្មោះ [redacted] រចនា , ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សារ៉ន់ ពិតជាបានចុះកិច្ចព្រមព្រៀងទិញដីភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ឃុំក្របៅ ទំហំ៣១៨ហិចតា ដោយក្នុង១ហិចតា តម្លៃ ៤៥០០$ ប្រាកដមែន ។ ចំពោះលុយដែលទទួលបានជាសែកចំនួនជាង២លាន ដុល្លារមែន ក្រុមហ៊ុនបានបើកឱ្យពួកខ្លួន និងបើកឱ្យម្ចាស់ដីផ្ទាល់ខ្លះ ។ ដោយសារដីឡើងថ្លៃជាបន្តបន្ទាប់ទើបធ្វើឱ្យពួកខ្លួនទិញដីពុំបានគ្រប់ចំនួន បានតែ ៣៨ហិចតា នៅឃុំក្របៅ និងឃុំក្រញូង ៦៨ហិចតា ប៉ុណ្ណោះ ។

៥-តាមចម្លើយរបស់មេធាវីឈ្មោះ [redacted] មនោរម្យ តំណាងឱ្យដើមបណ្តឹងឈ្មោះ [redacted] ស្រីអ៊ុយ, [redacted] តុង, [redacted] វ៉ាន់យូ , [redacted] អេង នៅអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានឆ្លើយថា៖ កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៧ និងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ កូនក្តីរបស់ខ្លួន បានចុះកិច្ចព្រមព្រៀងទិញលក់ដីជាមួយភាគីអ្នកលក់ដីមានឈ្មោះ [redacted] រចនា, [redacted] សារ៉ន់ [redacted] សុខុម និង [redacted] សុវណ្ណ លើផ្ទៃដីទំហំសរុបចំនួន ៤១០,៤៦ ហិចតា (បួនរយដប់ក្បៀសសែសិបប្រាំមួយ) ហិចតា ដែលដីទីតាំងទី១ មានទំហំសរុបចំនួន ២៣១,៤១ ហិចតា (ពីររយសាមសិបមួយក្បៀសសែសិបមួយ) ហិចតា មានទីតាំងស្ថិតនៅភូមិចំការចេក១ ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង និងដីទីតាំងទី២ មានទំហំ ១៧៩,០៥ (មួយរយចិតសិបប្រាំបួនក្បៀសសិប្បប្រាំ) ហិចតា មានទីតាំងស្ថិតនៅភូមិព្រៃខ្វលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង ។ គិតចាប់ពីថ្ងៃចុះកិច្ចសន្យាព្រមព្រៀងទិញលក់ដីលើកទី១ រហូតមកដល់ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៨ ភាគីអ្នកលក់ដីទាំងបួននាក់ខាងលើគឺមាន ឈ្មោះ [redacted] រចនា [redacted] សារ៉ន់ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ បានទទួលប្រាក់ថ្លៃទិញលក់ដីពីកូនក្តីខ្លួនជាបន្តបន្ទាប់អស់ចំនួន ២,០៣១,៣៨២$ (ពីរលានបីម៉ឺនមួយពាន់បីរយប៉ែតសិបពីរដុល្លារអាមេរិក) ប៉ុន្តែពុំមានដីប្រគល់អោយកូនក្តីខ្លួនឡើយ ។

៦-តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] វៀន បានឆ្លើយនៅអយ្យការថា៖ រយៈពេលកន្លងមកខ្លួនធ្លាប់បានឃើញឈ្មោះ [redacted] រចនា ទៅប្រមូលទិញដីពីប្រជាពលរដ្ឋនៅភូមិចំការចេក១ ភូមិក្រញូង ដែលមាន១២៤គ្រួសារ ប្រជាពលរដ្ឋក្រោម១ហិចតា ឃើញឈ្មោះ [redacted] រចនា ប្រគល់ប្រាក់ខ្លះនៅខ្លះ ចំណែកអ្នកដែលមានដីទំហំចាប់ពី ១ហិចតាឡើងទៅឈ្មោះ [redacted] រចនា ពុំទាន់បានប្រគល់ប្រាក់អោយទេ ក្នុងម្នាក់កក់ចំនួន ២០ដុល្លារអាមេរិក ។ ក្រោយមកប្រជាពលរដ្ឋមកសួរខ្លួនអំពីរឿងដែលឈ្មោះ [redacted] រចនា ទិញដីពីអ្នកទាំងនោះ ខ្លួនបានប្រាប់ទៅសួរឈ្មោះ [redacted] រចនា ហើយឈ្មោះ [redacted] រចនា បានប្រាប់ទៅភាគីអ្នកលក់ដីនោះថា គាត់ពុំមានប្រាក់អោយទេ គាត់សុំប្រគល់ដីឱ្យទៅម្ចាស់ដើមវិញ ។ ក្រោយមកក្រុមហ៊ុនបានមកសួរខ្លួនថា លុយនោះបានប្រគល់ជាង២លានហើយ ខាងក្រុមហ៊ុនសួរហេតុអ្វីមិនប្រគល់លុយនោះអោយអ្នកលក់ ហើយខ្លួនក៏បាននាំក្រុមហ៊ុនទៅសួរប្រជាពលរដ្ឋដែលជាអ្នកលក់ដី គាត់បានឆ្លើយថា ពុំទាន់បានទទួលប្រាក់ពីឈ្មោះ [redacted] រចនា ទេ ។

៧-តាមចម្លើយរបស់ជនត្រូវចោទ, មេធាវីតំណាងឱ្យដើមបណ្តឹង និងសាក្សី នៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ឃើញថា ជនត្រូវចោទពិតជាបានធ្វើសកម្មភាព ឆបោក ប្រាកដមែន ដូច្នេះអាចកំណត់បានថា សកម្មភាពដែលជនត្រូវចោទបានប្រព្រឹត្តនោះ គឺជាអំពើល្មើសច្បាប់ទៅនឹងមាត្រា ៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

៨-អំពើប្រព្រឹត្តរបស់ជនត្រូវចោទបានធ្វើអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម, ទ្រព្យសម្បត្តិឯកជន, របៀបរៀបរយសាធារណៈ និងសេចក្តីថ្លៃថ្នូររបស់រូបវ័ន្តបុគ្គល និងសង្គមដែលច្បាប់បានការពារ ។

៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនត្រូវចោទឈ្មោះ [redacted] រចនា, ឈ្មោះ [redacted] សារ៉ន់, ឈ្មោះ [redacted] សុខុម និងឈ្មោះ [redacted] សុវណ្ណ ពីបទ៖ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្វលថ្មី ន



Scanned with CamScanner

ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ [redacted]រចនា, ឈ្មោះ [redacted]សារន់, ឈ្មោះ [redacted]សុខុម និងឈ្មោះ [redacted]សុវណ្ណ ទៅជំនុំជម្រះពីបទ៖ ឆបោក ប្រព្រឹត្តនៅចំណុចភូមិចំការចេក១ ឃុំក្រញូង និងភូមិព្រៃខ្លូលថ្មី ឃុំក្របៅ ស្រុកកំចាយមារ ខេត្តព្រៃវែង បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ។ល

ថ្ងៃ.......ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ កុម្ភៈ ឆ្នាំ២០២១
ចៅក្រមស៊ើបសួរ
[redacted]

បានទទួលដំណឹង
ថ្ងៃ.......ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ កុម្ភៈ ឆ្នាំ២០២១
តំណាងអយ្យការ
[redacted]

ក្រឡាបញ្ជី
[redacted]



Scanned with CamScanner